## សេចក្ដីថ្លែងការណ៍រួម

## ស្ដីពីការដោះស្រាយវិវាទតាមរយៈដំណើរការ សម្រុះសម្រួលឯករាជ្យរវាងសហគមន៍ក្នុងស្រុកនៅក្នុង ឃុំ ប៊ូស្រា និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចវ៉ារ៉ាណាស៊ី និងក្រុមហ៊ុនសេដ្ឋីកុឡា (ក្រុមហ៊ុន សុកហ្វីន-ខេស៊ីឌី) និងក្រុមហ៊ុន កូវីផាម៉ា

នៅថ្ងៃទី...27.....ខែ...កញ្ញា.....ឆ្នាំ2022

## JOINT STATEMENT

## On dispute settlement through independent mediation between the local communities in Bousra Commune and the Economic Land Concessions Varanasi and Sethikula (Socfin-KCD company), and Coviphama.

On 27 September 2022

ដើម្បីអាចសម្រេចបាននូវកិច្ចព្រមព្រៀងស្ដីពីវិវាទដីធ្លី រវាងសមាជិកសហគមន៍ទាំងប្រាំនៅក្នុងឃុំប៊ូស្រា (ភូមិពូទឹត ភូមិពូរាំង ភូមិប៊ូស្រា ភូមិពូចា និងពូលុ) និងក្រុមហ៊ុន ភាគីទាំងអស់បានស្នើសុំឱ្យមានការចូលរួមដោះស្រាយ តាមដំណើរការសម្រុះសម្រួលដោយស្ម័គ្រចិត្ត។ សមាជិកសហគមន៍ដែលបានចូលរួមក្នុងដំណើរការនេះ បានជ្រើសរើសតំណាងរបស់ខ្លួនដើម្បីចូលរួមក្នុងកិច្ចប្រជុំចរចាជាមួយនឹងក្រុមហ៊ុនដែលបានធ្វើឡើងនៅក្នុងក្រុងសែនមនោរម្យ និងឃុំប៊ូស្រា ខេត្តមណ្ឌលគិរីនៅចន្លោះឆ្នាំ 2017 និងឆ្នាំ2021។

In order to find mutual agreements on land disputes between members of five communities in Busra Commune (Pu Teut, Pu Raing, Bousra, Pu Char and Pu Luk) and the companies, the parties requested to join a voluntary mediation process. Community members joining the process elected their representatives to join negotiation meetings with the company held in Sen Monorom city and Bousra Commune, Mondulkiri Province, between 2017 and 2021.

ដំណើរការសម្រុះសម្រួលនេះ មានគោលបំណងណែនាំពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធ និងជាគម្រោងសាកល្បងសម្រាប់ព្រះរាជាណាចក្រកម្ពុជា។ នេះគឺជាដំណើរការសហការដោយស្ម័គ្រចិត្ត ដែលភាគីទាំងពីរបានលើកឡើងអំពីបញ្ហាដែលបានរកឃើញ បង្កើតជម្រើស ជម្រើសដែលបានពិចារណា និងកិច្ចព្រមព្រៀងរួម។

The mediation aimed to introduce alternative conflict resolution and was a pilot project for the Kingdom. It was a voluntary collaborative process where the two parties identified issues, developed options, considered alternatives, and developed consensual agreements.

សហគមន៍ទទួលការណែនាំ និងការគាំទ្រពីអង្គការ Legal Aid of Cambodia (LAC) អ្នកសង្កេតការណ៍ និងសាក្សីដែលជាចាស់ទុំនៅក្នុងភូមិ មេឃុំប៊ូស្រា និងតំណាងការិយាល័យអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស

The communities received advice and support from the Legal Aid of Cambodia (LAC), and observers and witnesses included village elders, Bousra Commune Chief and the representative of the United Nations Office for Human Rights in Cambodia (UN OHCHR). The negotiations were

first class
in pursuit of speed and quality

ក្រុមហ៊ុន ហ្វឺស-ក្លាស សឺលូសិន អិលធីឌី ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

#306-308 វិថីពាណិជ្ជកម្ម ជីប ម៉ុង លែន (271) ភ្នំពេញ កម្ពុជា
+855 23 232 111 / 12 961 117 / 18 912 695 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(FCOP2022)

ភ្នំពេញ ថ្ងៃទី23 ខែកញ្ញា ឆ្នាំ2022
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ ... នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ... នៅក្នុងសំណៅនេះឡើយ។

FIRST-CLASS SOLUTIONS LTD

ចាន់ សុភាព ... លឹម គ្រួយ អគ្គនាយក

នៅក្នុងប្រទេសកម្ពុជា (UNOHCHR)។ ការចរចានេះ ត្រូវបានសម្រុះសម្រួលដោយក្រុមការងារសម្រុះសម្រួលឯករាជ្យ។

mediated by the Independent Mediation Team (IMG).

កិច្ចពិភាក្សានេះ ត្រូវបានធ្វើឡើងដាច់ដោយឡែកពីគ្នាសម្រាប់សហគមន៍នីមួយៗ និងបានរៀបចំឡើងតាមប្រភេទកាន់កាប់ដី។

ក្រុមហ៊ុន និងសហគមន៍ពូទិត ពូរាំង ប៊ូស្រា ពូចា និងពូលុ បានឯកភាពគ្នាចេញផ្សាយនូវសេចក្តីថ្លែងការណ៍រួមជាសាធារណៈដែលលើកឡើងអំពីសេចក្តីសម្រេចដែលបានចរចាគ្នា។

-------

Discussions were conducted separately for each community and organized by land tenure type.

The companies and the communities of Pu Teut, Pu Raing, Bousra, Pu Char and Pu Luk jointly agree to release this public joint-statement citing the following main negotiated resolutions.

-------

## 1. ការសម្រុះសម្រួលលើដីរួមសហគមន៍នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច

## 1. Mediation on communal land inside the Economic Land Concessions

ដើម្បីធ្វើឱ្យមានលក្ខណៈផ្លូវការទៅលើស្ថានភាពការពារ និងការកំណត់ព្រំប្រទល់នៃដីរួមសហគមន៍ដែលត្រូវបានការពាររួមគ្នាដោយសហគមន៍ និងក្រុមហ៊ុន និងដើម្បីដោះស្រាយបញ្ហានៃការទាមទារប្រភេទដីនេះ ដូច្នេះកិច្ចប្រជុំចរចាត្រូវបានរៀបចំឡើងចំពោះដីរួមសហគមន៍។

In order to officialise the protection status and boundaries on-site of communal land areas that are already jointly protected by the communities and the companies; and to address any further claims related to that type of land, negotiation meetings were organized about communal land.

ដីរួមសហគមន៍ រួមមានដីព្រៃអារក្ស ដីព្រៃតំណម ដីព្រៃខ្មោច និងដីព្រៃបម្រុងទុក។ ក្រុមហ៊ុន និងសហគមន៍ពូទិត ពូរាំង ប៊ូស្រា ពូចា និងពូលុ បានឯកភាពគ្នាទៅលើទីតាំង ទំហំ និងព្រំដីទំហំ 511 ហិចតានៃដីរួមសហគមន៍នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចនោះ។

Communal land included spirit forests, sacred forests, cemeteries and reserve land. The companies and the communities of Pu Teut, Pu Raing, Pu Char and Pu Luk have mutually agreed on the location, size and boundaries of 511 hectares of communal land within the ELCs.

តំណាងសហគមន៍បានឯកភាពគ្នាដាក់ពាក្យសុំចុះបញ្ជីដីទាំងនោះក្រោមប្រភេទដីរួមសហគមន៍ដល់រាជរដ្ឋាភិបាលដើម្បីឱ្យរដ្ឋាភិបាលទទួលស្គាល់ដីនោះស្របទៅតាមច្បាប់។

The representatives of the communities have agreed to submit an application for registration of these lands under communal land to the Royal Government in order to be recognized by the government and in accordance with the law.

ដីព្រៃបម្រុងទុក នឹងមិនត្រូវយកទៅអភិវឌ្ឍន៍នោះទេ ពោលគឺត្រូវចាំរហូតដល់ដែលអាជ្ញាធរពាក់ព័ន្ធចេញប្លង់

Reserve land areas will not be developed until the communal land titles for these areas are issued by the relevant authorities but

first class
in pursuit of speed and quality

ក្រុមហ៊ុន ហ្វើស-ក្លាស សឹលូសិន លីមីធីត ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

#306-308 វិថីពាណិជ្ជកម្ម ដឹប ម៉ុង លែន (271) ភ្នំពេញ កម្ពុជា
+855 23 232 111 / 12 961 117 / 18 912 695 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(FCOP2022)

ភ្នំពេញ ថ្ងៃទី23 ខែកញ្ញា ឆ្នាំ2022

FIRST CLASS SOLUTIONS LTD

ចាន់ សុ... លឹម គ្រុយ អគ្គនាយក

ដីរួមសហគមន៍នោះ ប៉ុន្តែសមាជិកសហគមន៍ អាចយកឃ្មុំនៅក្នុងតំបន់នោះបានតាមរយៈការប្រើប្រាស់វិធីសាស្ត្រផ្សេងៗក្រៅពីការប្រើភ្លើង និងប្រមូលអនុផលព្រៃឈើដូចជាទំពាំង ថ្នាំ ស្លឹកបៃតង វល្លិ ជ័រ អាហារ បន្លែ និងផ្លែឈើ។

community members can collect honey in these areas by using other methods aside from using fire, collect non-timer forest products such as bamboo shoots, medicine, green leaves, rattan, resins, food and vegetables and fruits.

ក្រុមហ៊ុននឹងបន្តដាក់ស្លាកសញ្ញាផ្តល់ព័ត៌មានអំពីស្ថានភាពការពារដីរួមសហគមន៍ ព្រមទាំងជូនដំណឹងតំណាងសហគមន៍អំពីបទល្មើសនានាដែលខ្លួនរកឃើញ។

The companies will continue to place boards with information on the protection status of communal land areas and will inform community representatives of any infraction noticed.

គម្រោងអភិវឌ្ឍន៍សហគមន៍ ដូចជាការធ្វើផ្លូវ និងការជីកអណ្តូងទឹក ក៏ត្រូវបានលើកឡើង និងឯកភាពគ្នានៅក្នុងសហគមន៍នីមួយៗផងដែរ។

Community development projects such as roads and water wells have been identified and agreed upon with each community.

## <u>2. ការសម្រុះសម្រួលលើដីតាមដងអូរ ក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច</u>

## <u>2. Mediation on land along the streams inside the ELCs</u>

កិច្ចប្រជុំសម្រុះសម្រួលនេះ ក៏បានធ្វើឡើង ដើម្បីពិភាក្សាអំពីករណីដីដែលសមាជិកសហគមន៍បានកាប់ដើម្បីធ្វើកសិកម្ម/ដាំដំណាំនៅតាមដងអូរ នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច។

Negotiation meetings were conducted to discuss the case of lands that community members cleared to cultivate along the streams in the Economic Land Concessions.

សមាជិកសហគមន៍មកពីពូទឺត ពូរាំង ពូចា និងពូលុ បានឯកភាពគ្នាក្នុងការកំណត់ផែនទីបរិវេណដែលពួកគេប្រមូលផលនៅតាមដងអូរនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វ៉ារ៉ាណាស៊ី និងក្រុមហ៊ុន សេដ្ឋីកុឡា (ក្រុមហ៊ុន សុកហ្វីន-ខេស៊ីឌី)។

Some community members from Pu Teut, Pu Raing, Pu Char and Pu Luk agreed to map the fields they are cultivating along the streams in the ELCs of Varanasi and Sethikula (Socfin-KCD company).

សហគមន៍ពូរាំង ពូចា ពូលុក នឹងដាក់ពាក្យសុំចុះបញ្ជីជាដីសមូហភាពសម្រាប់ចម្ការទាំងនេះ ហើយក្រុមហ៊ុននឹងមិនរំខានដល់ដំណើរការចុះបញ្ជីនេះឡើយ។

The communities of Pu Raing, Pu Char and Pu Luk will apply for registration as collective land for these fields and the company will not interfere with the registration process.

ដោយសារមានតែសមាជិកសហគមន៍ចំនួន 18 គ្រួសារ មកពីភូមិពូទឺតដែលបានចូលរួមក្នុងការសម្រុះសម្រួលដីតាមដងអូរ ពួកគាត់ភាគច្រើនបានទទួលលិខិតបញ្ជាក់កាន់កាប់ ដូច្នេះពួកគេមិនចុះបញ្ជីជាដីរួមនោះទេ។

With only 18 community members of Pu Tert participating in the mediation on land along the streams, most of them have already received ownership certificate, so they are not be registered as communal land.

សមាជិកសហគមន៍ នឹងមិនដាក់ពាក្យសុំចុះបញ្ជីដីជាន់លើចម្ការកៅស៊ូនោះទេ។

Members of the communities will not apply for the registration of land overlapping rubber fields.

តំណាងសហគមន៍ បានព្រមព្រៀង និងធានាថានឹងមិនមានការពង្រីកដីចម្ការថ្មីបន្ថែមទៀតដែលនៅតាមដងអូរនោះទេ ប៉ុន្តែអាចដាំដុះនៅលើផែនទីដីចម្ការសម្រាប់ការសម្រុះសម្រួលដែលបានទុកចោលឱ្យក្លាយទៅជាដីមានជីជាតិ។

The representatives of the communities have agreed and guaranteed that no further expansion of new farmlands along the streams will be carried out but can cultivate on farmland map for mediation where has been left to become fertile land.

សមាជិកសហគមន៍ បានឯកភាពថា ការកាប់រានដីថ្មី តាមរយៈការស្នើសុំទៅអាជ្ញាធរភូមិត្រូវតែបញ្ឈប់ ដោយសារតែអាជ្ញាធរភូមិ ឬមេភូមិ មិនមានសិទ្ធិក្នុងការអនុញ្ញាតឱ្យសហគមន៍កាប់រានដីព្រៃដើម្បីធ្វើកសិកម្មនៅតាមដងអូរដែលបានការពារនោះទេ។ ប្រសិនបើមានការកាប់រានដីថ្មីកើតមានឡើង នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការរាយការណ៍ និងជូនដំណឹងដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់។

Members of the communities agreed that the new forest clearance as per the request to the village authority shall be stopped because the village authority or village chief does not have the right to allow the community to clear forest land for cultivation along the protected rivers. If new land clearance occurs within the economic land concessions, the company has the obligation to report and notify the authorities at all levels.

ក្រុមហ៊ុននឹងធានាថា សកម្មភាពរបស់ខ្លួននឹងមិនប៉ះពាល់ដល់ដំណាំដែលបានដាំនៅលើដីចម្ការនោះទេ។ ពួកគេមិនឈូសឆាយដីចម្ការ ឬដីតាមដងអូរនោះទេ។

The company will ensure its activities do not affect crops planted on these farmlands. They will not clear these farmlands or other land along the streams.

ក្រុមហ៊ុន មិនមានគោលការណ៍បិទផ្លូវនោះទេ ដូច្នេះក្រុមហ៊ុនអនុញ្ញាតឱ្យសហគមន៍ចេញចូលតំបន់ដីសម្បទានសេដ្ឋកិច្ចបានដោយសេរី។ សមាជិកសហគមន៍ ត្រូវតែឆ្លងកាត់ច្រកទ្វាររបស់ក្រុមហ៊ុន ដែលមានការត្រួតពិនិត្យមួយចំនួនដើម្បីការពារសន្តិសុខ។

The company does not have a road closure policy, so the company allows the community to freely enter and exit the ELCs. Community members must pass through the companies' gates, with only a few checkpoints for security protection.

សហគមន៍ យល់ព្រមជូនដំណឹងដល់ក្រុមហ៊ុនទាន់ពេលវេលាអំពីការដុតដីចម្ការ (ការកាត់ និងដុតតាមបែបប្រពៃណី)។ ពួកគេនឹងមិនដុតព្រៃដើម្បីកាប់រានដីថ្មីឡើយ។ ភាគីទាំងសងខាង នឹងផ្តល់ព័ត៌មានទៅឱ្យគ្នាទៅវិញទៅមក នឹងសហការគ្នាដើម្បីការពារការរីករាលដាលភ្លើងឆេះព្រៃ។

The communities agreed to inform the company on the time of burning their fields (slash and burn tradition). They will not burn forests for new land clearance. Both parties will provide information to each other and cooperate for the prevention of spread of wildfires.

first class
in pursuit of speed and quality

ក្រុមហ៊ុន ហ្វឺស-ក្លាស សឹលូសិន និលធីឌី ចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 13113/09P នៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

#306-308 វិថីពាណិជ្ជកម្ម ជីប ម៉ុង លែន (271) ភ្នំពេញ កម្ពុជា
+855 23 232 111 / 12 961 117 / 18 912 695 / 78 567 863
fcinfo@firstclass.com.kh | www.firstclass.com.kh
(FCOP2022)

ភ្នំពេញ ថ្ងៃទី23 ខែកញ្ញា ឆ្នាំ2022
ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែនេះពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ [illegible] នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពី [illegible] នៅក្នុងសំណៅនេះឡើយ។

ចាន់ សុភា [illegible] ... លីម គ្រុយ អគ្គនាយក

## 3. ការសម្រុះសម្រួលលើដីចម្ការកៅស៊ូគ្រួសារ (កសិករខ្នាតតូច)

## 3. Mediation on rubber families (smallholders)

តំណាងសហគមន៍ និងក្រុមហ៊ុន វ៉ារ៉ាណាស៊ី និងក្រុមហ៊ុន សេធីកុឡា (ក្រុមហ៊ុន សុកហ្វីន-ខេស៊ីឌី) បានចូលរួមក្នុងការប្រជុំចរចា ដើម្បីពិភាក្សាអំពីកិច្ចព្រមព្រៀងបច្ចុប្បន្ន និងកាតព្វកិច្ចពាក់ព័ន្ធរវាងគ្រួសារដាំកៅស៊ូ និងក្រុមហ៊ុន។

Community representatives and Varanasi and Sethikula (Socfin-KCD company) joined negotiation meetings to discuss the current agreements and related obligations between rubber families and the companies.

សមាជិកសហគមន៍មកពីភូមិពូទឹត ភូមិពូរាំង ភូមិពូចា និងភូមិពូលុ និងក្រុមហ៊ុន នឹងពិភាក្សាគ្នាអំពីកិច្ចព្រមព្រៀងថ្មី។ សមាជិកសហគមន៍ អាចស្នើសុំការគាំទ្រពីមេធាវី ភាគីពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការសិក្សាអំពីមូលដ្ឋានរួមរវាងសហគមន៍ និងក្រុមហ៊ុនដែលអាចនឹងឈានទៅដល់កិច្ចព្រមព្រៀងនាពេលអនាគត។

Community members from Pu Teut, Pu Raing, Pu Char and Pu Luk villages and the company will discuss on a new agreement. Community members can ask support from lawyer, stakeholders or non-governmental organizations to study common ground between the community and the company that can lead to future agreements.

ក្រុមហ៊ុននឹងមិនបញ្ចូលថ្លៃជួលនៅក្នុងកិច្ចព្រមព្រៀងថ្មីនោះទេ ហើយបំណុលរបស់សមាជិកសហគមន៍ដែលបានចុះឈ្មោះចូលទៅក្នុងគម្រោងនេះ នឹងត្រូវគណនាដោយផ្អែកលើទំហំបច្ចុប្បន្នក្រោមកិច្ចព្រមព្រៀង។ គ្រប់ភាគីទាំងអស់បានឯកភាពទៅលើទំហំដីចម្ការកៅស៊ូគ្រួសារនោះ។

The company will not include a rental fee in the new agreement and the debt of community members who entered in this project will be calculated based on the current size under the agreement. All parties have agreed on the size of the family rubber plantation land

សមាជិកសហគមន៍ ដែលនៅក្នុងគម្រោងនេះ អាចបន្តលក់កៅស៊ូ ទៅឱ្យក្រុមហ៊ុនផ្សេង ឬភាគីទីបីបាន។

Members of the communities who are in the project can continue to sell rubber to other companies or third parties.

ក្រុមហ៊ុនសូមសន្យា និងធានាថា ខ្លួននឹងមិនរឹបអូសដីចម្ការកៅស៊ូគ្រួសារនេះពីសហគមន៍ក្នុងអំឡុងពេលកិច្ចសន្យារវាងក្រុមហ៊ុន និងរដ្ឋាភិបាលនោះទេ លើកលែងតែរដ្ឋាភិបាលដកសិទ្ធិកាន់កាប់តំបន់ដីសម្បទានសេដ្ឋកិច្ចនេះវិញ។ ប្រសិនបើក្រុមហ៊ុនបញ្ចប់លក្ខខណ្ឌដីសម្បទានសេដ្ឋកិច្ច នោះខ្លួនក៏បញ្ចប់កាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងសហគមន៍ផងដែរ។

The company has promised and guaranteed that it will not confiscate the family rubber plantation land from the communities during the contract period between the company and the government, except for the government revoking the economic land concessions rights. If the company terminates the term of the economic land concessions with the government, it also terminates all the obligations stipulated in the agreement between the company and the communities.

ក្នុងករណីដែលរដ្ឋាភិបាល យល់ព្រមបន្តកិច្ចព្រមព្រៀងដីសម្បទានសេដ្ឋកិច្ចនេះជាមួយក្រុមហ៊ុននាពេល

In case the government agrees to renew the economic land concessions agreements with the

អនាគត ក្រុមហ៊ុនសូមទុកសិទ្ធិឱ្យសហគមន៍ជាអ្នកសម្រេចចិត្តថាតើត្រូវបន្តកិច្ចព្រមព្រៀងចម្ការកៅស៊ូគ្រួសារឬយ៉ាងណា។ ក្នុងករណីដែលសហគមន៍មិនចង់បន្តកិច្ចសន្យាជាមួយក្រុមហ៊ុន ពួកគេអាចយកដីចម្ការកៅស៊ូគ្រួសារដែលបានគ្រប់គ្រងពីមុនមក ដើម្បីដាក់ពាក្យសុំចុះបញ្ជីជាមួយរដ្ឋាភិបាលថាជាដីរួម។

company in the future, the company reserve the rights for the communities to make a decision to renew the family rubber plantation agreement. In case the communities do not want to renew the contract with the company, they can take the family rubber plantation land which was previously managed to apply for land registration with the government as a collective land.

កិច្ចព្រមព្រៀងនេះ អាចនឹងបញ្ចប់ដោយគោលការណ៍ស្ម័គ្រចិត្ត និងការផ្លាស់ប្តូរដីអាចធ្វើឡើងបាន ប្រសិនបើមានការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត។

Agreements can be ended on a voluntary basis and relocation of plots can be done, if mutually agreed, on a voluntary basis.

ក្រុមហ៊ុននឹងធ្វើការជួសជុលផ្លូវប្រវែង 100 ម៉ែត្រជារៀងរាល់ឆ្នាំ។ ក្នុងករណីដែលក្រុមហ៊ុនរកឃើញថាសមាជិកសហគមន៍ណាមួយធ្វើឱ្យខូចផ្លូវ នោះខ្លួននឹងធ្វើការរាយការណ៍ជូនអ្នកតំណាងភូមិទាំងបួន។ អ្នកតំណាង បានព្រមព្រៀងក្នុងការផ្តល់ការណែនាំដល់អ្នកដែលធ្វើឱ្យខូចផ្លូវ។ គ្រប់ភាគីទាំងអស់បានព្រមព្រៀងគ្នាមិនធ្វើការបិទផ្លូវ ហើយអនុញ្ញាតឱ្យសន្តិសុខរបស់ក្រុមហ៊ុនពិនិត្យ និងសាកសួរនៅពេលឆ្លងកាត់ផ្លូវចូលទៅកាន់ចម្ការកៅស៊ូគ្រួសារ។

The company will repair 100 meter of road every year. In case the company finds any member of the communities damaging the road, it will report to the representatives of the four villages. The representatives have agreed to advise those who damage the road. All parties have agreed not to block the road and authorise the security team of the company to check and interrogate when crossing the road to the family rubber plantations.

**<u>4. ការសម្រុះសម្រួលលើដីចម្ការពាក់ព័ន្ធ</u>**

**<u>4. Mediation on related farmland</u>**

កិច្ចព្រមព្រមព្រៀងរវាងក្រុមហ៊ុន វ៉ារ៉ាណាស៊ី និងក្រុមហ៊ុនក្រុមហ៊ុន សេដ្ឋីកុឡា (ក្រុមហ៊ុន សុកហ្វីន-ខេស៊ីឌី) និងសហគមន៍មកពីភូមិពូទឹត ភូមិពូរាំង ភូមិប៊ូស្រា ភូមិពូចា និងភូមិពូលុ ដោះស្រាយទៅលើការទាមទារពីសមាជិកសហគមន៍សម្រុះសម្រួលពីដីដែលត្រូវបានរាយការណ៍ពីមុនថាមិនបានទទួលសំណង និងទាមទារពីសមាជិកសហគមន៍សម្រុះសម្រួលពាក់ព័ន្ធនឹងប្រភេទសំណងដែលទទួលបានមុនកិច្ចព្រមព្រៀងនេះ។

These agreements between Varanasi and Sethikula (Socfin-KCD company) and the communities of Pu Teut, Pu Raing, Bousra, Pu Char and Pu Luk resolve claims from mediation community members for land that was reportedly not compensated and claims from the mediation community members regarding any type of compensation received prior to this agreement.

ក្រុមហ៊ុន ព្រមព្រៀងផ្តល់ជូនសហគមន៍នីមួយៗនូវថវិកាសហគមន៍ជារៀងរាល់ឆ្នាំ។ ចំនួនទឹកប្រាក់ថវិកានេះ ត្រូវបានព្រមព្រៀងគ្នាទៅតាមសហគមន៍នីមួយៗដាច់ដោយឡែកពីគ្នា។

The company agrees to provide each community with a community budget every year. The amount of the budget has been agreed upon for each community separately.

The budget will be allocated for a limited period agreed on with each community.

មូលនិធិប្រចាំឆ្នាំ នឹងត្រូវប្រើប្រាស់សម្រាប់សកម្មភាពអភិវឌ្ឍន៍សហគមន៍ (គម្រោង) ដើម្បីផ្តល់ជូនគ្រួសារនៅក្នុងសហគមន៍ដែលចូលរួមក្នុងដំណើរការសម្រុះសម្រួលនេះ។ ប្រសិនបើថវិកាប្រចាំឆ្នាំសរុបដែលក្រុមហ៊ុនបានផ្តល់ជូន មិនបានចំណាយអស់ទេ នោះទឹកប្រាក់ដែលនៅសល់នឹងត្រូវចរចាគ្នាឡើងវិញរវាងក្រុមហ៊ុន និងសហគមន៍ ក្រោយពេលបញ្ចប់រយៈពេលបែងចែកថវិកាដែលបានព្រមព្រៀងគ្នា។

The annual fund will be used for community development activities (projects) to serve the families of the communities involved in the mediation process. If the total annual fund provided by the company is not fully spent, the remaining fund and how it will be spent will be renegotiated between the company and the community after the end of the allocation period agreed upon.

ថវិកាប្រចាំឆ្នាំនេះ នឹងត្រូវប្រើប្រាស់ដើម្បីអនុវត្តសកម្មភាពអភិវឌ្ឍន៍សហគមន៍ (គម្រោង) ដើម្បីជួយដល់គ្រួសារដែលចូលរួមនៅក្នុងដំណើរការសម្រុះសម្រួលនេះ។

The annual fund will be used to implement community development activities (projects) to serve the families involved in the mediation process.

សកម្មភាពអភិវឌ្ឍន៍សហគមន៍ អាចគ្របដណ្តប់លើប្រធានបទជាច្រើន ដោយមិនកំណត់ទៅលើតែការងារហេដ្ឋារចនាសម្ព័ន្ធ ការគាំទ្រផ្នែកកសិកម្ម ការអភិវឌ្ឍជំនាញ គម្រោងចិញ្ចឹមជីវិត សកម្មភាពអេកូទេសចរណ៍ ជំនួយសង្គ្រោះបន្ទាន់ ឬជំនួយជាថវិកាដល់ទៅមូលនិធិគ្រប់គ្រងដោយសហគមន៍។

The community development activities can cover a wide range of topics, including but not limited to infrastructures, agricultural support, education, skill development, livelihood projects, ecotourism activities, emergency assistance or financial assistance to a community-managed fund.

ការបែងចែកសាច់ប្រាក់ទៅឱ្យមូលនិធិគ្រប់គ្រងដោយសហគមន៍ នឹងមិនត្រូវលើសពី 25% នៃថវិកាប្រចាំឆ្នាំ។

Cash contributions to a community-managed fund will not exceed 25% of the annual fund.

ការអនុវត្តគម្រោងនីមួយៗ នឹងត្រូវយកមកពិភាក្សារវាងក្រុមហ៊ុន និងសហគមន៍ដែលស្នើសុំ បន្ទាប់ពីការស្នើនោះត្រូវបានបញ្ជូនទៅ និងចុះហត្ថលេខាដោយតំណាងសហគមន៍ទាំងអស់។

The implementation of each project will be discussed between the company and the requesting community after a request is sent and signed by all representatives of the community.

----

-----

តាមរយៈដំណោះស្រាយដែលបានព្រមព្រៀងគ្នាក្នុងអំឡុងពេលដំណើរការសម្រុះសម្រួលនេះ និងដែលបានរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍រួម ភាគីទាំងអស់បានធ្វើការដោះស្រាយគ្រប់បណ្តឹងទាំងអស់ដែលពាក់ព័ន្ធនឹងករណីដែលបានចរចាគ្នា។

Through the solutions agreed upon during the mediation process and listed in this joint-statement, all parties have resolved together all grievances related to the cases negotiated.

ភាគីក្រុមហ៊ុន

**Company Party**

ក្រុមហ៊ុន វ៉ារ៉ាណាស៊ី

**Varanasi Company**

Mr. Shanid Aluppy [redacted]

ក្រុមហ៊ុន សេដ្ឋីកុឡា

**Sethikula Company**

Mr. Shanid Aluppy [redacted]

ក្រុមហ៊ុន កូវីផាម៉ា

**Coviphama Company**

Mr. Shanid Aluppy [redacted]

ភាគីសហគមន៍ចូលរួមចរចា

**Mediated Community Parties**

តំណាងសហគមន៍ភូមិពូរាំង

**Pu Raing Community Representatives**

| | | | | |
|---|---|---|---|---|
| ពើស គួយ | ត្រាក តក | ស្រូល វ៉ាន់ | ប៉ី ដេង | ក្រោស ក្រើប |
| **Poeurs Kouy** | **Trak Tork** | **Srol Van** | **Pey Deng** | **Krors Kroeurb** |

តំណាងសហគមន៍ភូមិពូលុ

**Pu Lu Community Representatives**

| | | | | |
|---|---|---|---|---|
| ឈឹង វឿង | ព្យឿល នៀន | មើល ងើវ | ម៉ាលី គីម | ងេះ ណាំ |
| **Chhoeng Voeurng** | **Pyoeurl Nien** | **Moeurl Ngev** | **Maly Kim** | **Nge Nam** |

## តំណាងសហគមន៍ភូមិចា

**Pu Char Community Representatives**

ប្រប់ ទុច — **Brop Tuch Nheb**

ព្រុត ថា — **Prut Tha**

ខ្លឹក កែវស៊ីងៀប — **KhleoK Keosingieb**

ព្រៃ ត្រេ — **Prey Tre**

រួយ ទើប — **Rouy Teurb**

ពៀស ញែប — **Pcheus**

## តំណាងសហគមន៍ភូមិពូទឹត

**Pu Tert Community Representatives**

ង៉ាង យ៉ិន — **Ngang Yin**

កប់ លេត — **Korb Let**

កេត ផល្លិត — **Ket Phallit**

ធីន ស៊ីម៉ា — **Thin Sima**

ធឿន ម៉ាប់ — **Theoun Mab**

## តំណាងសហគមន៍ភូមិប៊ូស្រា

**Busra Community Representatives**

ប្រុង ទើច — **Brong Toeurch**

ឆើច បែន — **Chhoeurch Ben**

ប៉ាក់ ខឿន — **Pak Khoeun**